

មគ្គទេសក៍សម្រាប់បង្រៀនទំនងខ្មែរ



ប្រវត្តិវិទ្យា



© រក្សាសិទ្ធគ្រប់បែបយ៉ាងដោយ

លោក ឈិន ចណ្ឌី

ហាមដកស្រង់ខ្លឹមសារទាំងស្រុងក្នុងផ្នែកណាមួយនៃសៀវភៅនេះយកទៅរៀបរៀងធ្វើជាសៀវភៅផ្ទាល់ខ្លួនសម្រាប់ធ្វើអាជីវកម្ម ដោយគ្មានការអនុញ្ញាត។

បោះពុម្ពលើកទី១

អារម្ភកថា

សៀវភៅ**«មគ្គទេសក៍សម្រាប់បង្រៀន និងរៀន ប្រវត្តិវិទ្យា ថ្នាក់ទី៧»** នេះ ជាសៀវភៅដ៏ល្អមួយសម្រាប់សិស្សានុសិស្សយកមកធ្វើជាមគ្គទេសក៍សម្រាប់រៀន និងជាឯកសារជំនួយស្មារតី ដើម្បីឱ្យយល់ពីខ្លឹមមេរៀននីមួយៗកាន់តែច្បាស់លាស់បន្ថែមទៀត។ ទន្ទឹមនឹងនេះលោកគ្រូ អ្នកគ្រូ ក៏អាចយកសៀវភៅនេះមកធ្វើជាមគ្គទេសក៍សម្រាប់បង្រៀនសិស្សបានផងដែរ ព្រោះសៀវភៅនេះខ្ញុំបានរៀបចំឡើងតាមលំដាប់លំដោយនៃខ្លឹមសារមេរៀននីមួយៗគ្រប់ចំណុចទាំងអស់ ដែលមាននៅក្នុងសៀវភៅសិក្សាគោលថ្មី។

កូនសៀវភៅដ៏តូចស្តើងនេះកើតចេញពីការប្រមូលផ្តុំនូវចំណេះដឹងសំខាន់ៗពីលោកគ្រូ អ្នកគ្រូ ដែលបានបង្ហាត់បង្រៀនខ្ញុំ បានកន្លងមក ព្រមទាំងការចម្រាញ់ចេញពីឯកសារនានាដែលខ្ញុំ ធ្លាប់បានអានស្រាវជ្រាវ និងការសម្រិតសម្រាំងតាមខ្លឹមសារមេរៀនដែលមាននៅក្នុងសៀវភៅប្រវត្តិវិទ្យាថ្នាក់ទី៧ របស់ក្រសួងអប់រំ យុវជន និងកីឡា។ ខ្ញុំបានចងក្រងសៀវភៅនេះឡើង ដើម្បីធ្វើជាមគ្គទេសក៍សម្រាប់បង្រៀនរបស់ខ្ញុំផ្ទាល់ខ្លួន និងទុកជាឯកសារជំនួយស្មារតីដល់សិស្សានុសិស្សសម្រាប់ស្រាវជ្រាវបន្ថែម។

ទោះបីជាខ្ញុំខិតខំព្យាយាមសម្រិតសម្រាំងយ៉ាងណាក៏ដោយ ក៏នៅតែមានចំណុចខ្វះខាតដោយជៀសវាំងមិនរួចនោះឡើយ ដូច្នេះខ្ញុំសង្ឃឹមថាសិស្សានុសិស្ស និស្សិត លោកគ្រូ អ្នកគ្រូ និងអ្នកសិក្សាទាំងឡាយមេត្តាយោគយល់អធ្យាស្រ័យចំពោះកំហុសឆ្គងទាំងនេះដោយក្តីអនុគ្រោះ និងចូលរួមរិះគន់ដើម្បីស្ថាបនាដើម្បីឱ្យសៀវភៅនេះកាន់តែល្អទ្វេឡើង នៅពេលបោះពុម្ពលើកក្រោយៗទៀត។ សូមអរគុណ!


ខេត្តកំពត ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៥

លោក ឈិន ចណ្ឌី



ជូនចំពោះ

.....



“សៀវភៅជាកាដូដ៏មានតម្លៃសម្រាប់មនុស្សជាទីស្រឡាញ់របស់អ្នក”



មាតិកា

ផ្នែកទី១ សំណួរ-ចម្លើយលម្អិតតាមចំណុចនីមួយៗ

ជំពូកទី១ ប្រវត្តិសាស្ត្រកម្ពុជាសម័យបុរេប្រវត្តិ មុនអង្គរ និងអង្គរ

មេរៀនទី១ មូលដ្ឋាននៃការសិក្សាប្រវត្តិវិទ្យា

១-ពាក្យគន្លឹះ..... ១

២-ប្រវត្តិវិទ្យាជាអ្វី ? ១

២.១-និយមន័យ..... ១

២.២-ឯកសារប្រវត្តិវិទ្យា ២

២.៣-សារៈសំខាន់នៃប្រវត្តិវិទ្យា..... ៣

៣-កាលវិទ្យា..... ៣

៣.១-និយមន័យ ៣

៣.២-របៀបចែកកាល..... ៤

៣.៣-កាលសម័យធំៗនៃប្រវត្តិសាស្ត្រ ៧

៤-កាលសម័យបុរេប្រវត្តិសាស្ត្រ ៨

៤.១-យុគសម័យ..... ៨

៤.២-ជីវភាពសង្គម..... ៩

៥-មេរៀនសង្ខេប..... ១៤

៦-សំណួរប្រតិបត្តិ..... ១៤

មេរៀនទី២ បុរេប្រវត្តិសាស្ត្រកម្ពុជា

១-ពាក្យគន្លឹះ..... ១៦

២-ដើមកំណើតទឹកដីខ្មែរ ១៧

៣-ដើមកំណើតនៃជនជាតិខ្មែរ ១៨

៤-ផែនទីស្ថានីយបុរេប្រវត្តិសាស្ត្រកម្ពុជា ១៩

៥-យុគសម័យ និងស្ថានីយបុរេប្រវត្តិសាស្ត្រកម្ពុជា ២០

៦-អរិយធម៌ខ្មែរសម័យបុរេប្រវត្តិសាស្ត្រ ២២

៧-សង្ខេបមេរៀន ២៣

៨-សំណួរប្រតិបត្តិ ២៣

មេរៀនទី៣ អាណាចក្រភ្នំ ឬហ្វូណន(៥០-៥៥០)

១-ពាក្យគន្លឹះ ២៤

២-បញ្ហាឈ្មោះរដ្ឋខ្មែរដំបូង ២៦

៣-រឿងព្រេងទាក់ទងដើមកំណើតរដ្ឋខ្មែរដំបូង ២៧

៤-ទីតាំងភូមិសាស្ត្រ ២៨

៥-កំណរកំណើតរដ្ឋ ២៩

៦-ឥទ្ធិពលឥណ្ឌាលើអាណាចក្រភ្នំ ៣០

៧-ព្រះរាជាល្បីៗសម័យអាណាចក្រភ្នំ ៣១

៨-បញ្ហាការសរសេរព្រះនាមព្រះរាជាខ្មែរ ៣៣

៩-ការចុះខ្សោយនៃអំណាចអាណាចក្រភ្នំ ៣៥

១០-អរិយធម៌អាណាចក្រភ្នំ ៣៦

១១-មេរៀនសង្ខេប ៤២

១២-សំណួរប្រតិបត្តិ ៤២

មេរៀនទី៤ អាណាចក្រចេនឡា (៥៥០-៨០២)

១-ពាក្យគន្លឹះ..... ៤៣

២-ទីតាំងភូមិសាស្ត្រ..... ៤៤

៣-បញ្ហាឈ្មោះចេនឡា..... ៤៤

៤-ព្រះរាជាល្បីៗនៅអាណាចក្រចេនឡា..... ៤៥

៥-ការបែកបាក់អាណាចក្រចេនឡា..... ៤៦

៦-ចេនឡាដីគោក..... ៤៩

៧-ចេនឡាទឹកលិច..... ៤៩

៨-អរិយធម៌ចេនឡា..... ៤៩

៩-មេរៀនសង្ខេប..... ៥៧

១០-សំណួរប្រតិបត្តិ..... ៥៧

មេរៀនទី៥ ចក្រភពអង្គរ

១-ពាក្យគន្លឹះ..... ៥៨

២-ក្សត្រស្ថាបនិកទី១នៃសម័យអង្គរ..... ៥៩

៣-ព្រះរាជាល្បីៗនៅចក្រភពអង្គរ..... ៦១

៤-វិស័យសេដ្ឋកិច្ច..... ៦៣

៥-វិស័យនយោបាយ និងរដ្ឋបាល..... ៦៥

៦-វិស័យសង្គម..... ៦៦

៧-សាសនា សិល្បៈ និងលទ្ធិផ្សេងៗ..... ៦៧

៨-មេរៀនសង្ខេប..... ៧០
៩-សំណួរប្រតិបត្តិ..... ៧០

ជំពូកទី២ ប្រវត្តិសាស្ត្រតំបន់សម័យបុរាណ

មេរៀនទី១ ចិនបុរាណ

១-ពាក្យគន្លឹះ..... ៧២
២-ប្រភពប្រវត្តិសាស្ត្រចិន..... ៧២
៣-រាជវង្សដើម..... ៧៤
៤-រាជវង្សស៊ូ..... ៧៥
៥-ចិនបុរាណ(ទស្សនៈ សង្គម និងជំនឿសាសនា)..... ៧៧
៦-មេរៀនសង្ខេប..... ៨១
៧-សំណួរប្រតិបត្តិ..... ៨១

មេរៀនទី២ ឥណ្ឌាបុរាណ

១-ពាក្យគន្លឹះ..... ៨២
២-ទីតាំងភូមិសាស្ត្រ និងជនជាតិ..... ៨២
៣-អរិយធម៌តាមដងទន្លេឥណ្ឌុស..... ៨៤
៤-ការលុកលុយរបស់ពួកអារ្យែន(២០០០-១៥០០ឆ្នាំមុនគ.ស.)..... ៨៥
៥-អរិយធម៌ឥណ្ឌា-អារ្យែន..... ៨៦
៦-មេរៀនសង្ខេប..... ៨៩
៧-សំណួរប្រតិបត្តិ..... ៨៩

មេរៀនទី៣ រដ្ឋជ្វា

១-ពាក្យគន្លឹះ..... ៩០

២-កំណើតរដ្ឋជ្វា ៩០

៣-ឥទ្ធិពលសាសនាអ៊ិស្លាម(ចាប់ពីសតវត្សទី១៤ដល់១៨) ៩១

៤-ឥទ្ធិពលក្រុមហ៊ុនឥណ្ឌាខាងកើតលើកោះជ្វា ៩៣

៥-អរិយធម៌កោះជ្វា ៩៤

៦-មេរៀនសង្ខេប ៩៥

៧-សំណួរប្រតិបត្តិ ៩៥

មេរៀនទី៤ រដ្ឋមន

១-ពាក្យគន្លឹះ ៩៦

២-ស្ថានភាពជនជាតិមន និងខ្មែរ ៩៦

៣-កំណើតរដ្ឋមន ៩៧

៤-ទំនាក់ទំនងរវាងមន-ភូមានិងមន-សៀម(ស.វ.ទី៩-សព្វថ្ងៃ) ៩៨

៥-មេរៀនសង្ខេប ១០០

៦-សំណួរប្រតិបត្តិ ១០០

ជំពូកទី៣ ពិភពលោកសម័យបុរាណ

មេរៀនទី១ អេហ្ស៊ីបបុរាណ

១-ពាក្យគន្លឹះ ១០២

២-ស្ថានភាពភូមិសាស្ត្រ ១០២

៣-ប្រវត្តិសាស្ត្រអេហ្ស៊ីប ១០៤

៤-វណ្ណៈសង្គម ១០៩

៥-សាសនាអេហ្ស៊ីបបុរាណ ១១១

៦-មេរៀនសង្ខេប ១១៣

៧-សំណួរប្រតិបត្តិ ១១៣

មេរៀនទី២ រដ្ឋនៅតំបន់មេសូប៉ូតាមី

១-ពាក្យគន្លឹះ..... ១១៤

២-ទីតាំងភូមិសាស្ត្រ និងកុលសម្ព័ន្ធ..... ១១៥

៣-រដ្ឋមានឥទ្ធិពល និងនយោបាយវាទី ១១៦

៤-អរិយធម៌មេសូប៉ូតាមី..... ១១៨

៥-មេរៀនសង្ខេប..... ១២៣

៦-សំណួរប្រតិបត្តិ..... ១២៣

មេរៀនទី៣ ជនជាតិដើមអ៊ីស្រាអែល

១-ពាក្យគន្លឹះ..... ១២៤

២-ប្រវត្តិទឹកដី និងជនជាតិ..... ១២៤

៣-សម័យកាលសំខាន់ៗ..... ១២៨

៤-អរិយធម៌ហេប្រឺ..... ១៣០

៥-មេរៀនសង្ខេប..... ១៣២

៦-សំណួរប្រតិបត្តិ..... ១៣២

មេរៀនទី៤ រដ្ឋផេនីស៊ី

១-ពាក្យគន្លឹះ..... ១៣៤

២-ទីតាំងភូមិសាស្ត្រ..... ១៣៤

៣-ជីវភាពប្រជាជន ១៣៥

៤-អរិយធម៌ ១៣៦

៥-មេរៀនសង្ខេប..... ១៤០

៦-សំណួរប្រតិបត្តិ ១៤០

មេរៀនទី៥ ក្រិកបុរាណ

១-ពាក្យគន្លឹះ ១៤១

២-ស្ថានភាពភូមិសាស្ត្រ និងប្រជាជន ១៤១

៣-រដ្ឋបុរីនានា ១៤២

៤-អរិយធម៌ក្រិក និងពលរដ្ឋសកល ១៤៤

៥-មេរៀនសង្ខេប ១៤៨

៦-សំណួរប្រតិបត្តិ ១៤៨

មេរៀនទី៦ ចក្រភពរ៉ូម

១-ពាក្យគន្លឹះ ១៤៩

២-ស្ថានភាពទូទៅនៃចក្រភពរ៉ូម ១៤៩

៣-ព្រឹត្តិការណ៍នយោបាយ ១៥០

៤-អរិយធម៌រ៉ូម ១៥៣

៥-មេរៀនសង្ខេប ១៥៦

៦-សំណួរប្រតិបត្តិ ១៥៦

មេរៀនទី៧ អរិយធម៌អាម៉េរិកបុរាណ

១-ពាក្យគន្លឹះ ១៥៧

២-ចក្រភពម៉ាយ៉ា (Maya) ១៥៧

៣-ចក្រភពអាស្តែក (Aztéque) ១៦០

៤-ចក្រភពអាំងកា (Inca) ១៦២

៥-មេរៀនសង្ខេប ១៦៣

៦-សំណួរប្រតិបត្តិ ១៦៣

ផ្នែកទី២ វិញ្ញាសាប្រតិបត្តិសម្រាប់ហ្វឹកហាត់ត្រៀមប្រឡង

- ✍ វិញ្ញាសាប្រតិបត្តិទី១ .... ១៦៦
- ✍ វិញ្ញាសាប្រតិបត្តិទី២ .... ១៦៨
- ✍ វិញ្ញាសាប្រតិបត្តិទី៣ .... ១៧០
- ✍ វិញ្ញាសាប្រតិបត្តិទី៤ .... ១៧២
- ✍ វិញ្ញាសាប្រតិបត្តិទី៥ .... ១៧៤
- ✍ វិញ្ញាសាប្រតិបត្តិទី៦ .... ១៧៦
- ✍ វិញ្ញាសាប្រតិបត្តិទី៧ .... ១៧៨
- ✍ វិញ្ញាសាប្រតិបត្តិទី៨ .... ១៨០
- ✍ វិញ្ញាសាប្រតិបត្តិទី៩ .... ១៨២
- ✍ វិញ្ញាសាប្រតិបត្តិទី១០ .... ១៨៤

ឯកសារយោង .....

មតិអ្នកសិក្សា .....

ទំនាក់ទំនង .....

ថ្ងៃកទី១



សំណួរ-ចម្លើយលម្អិត

តាមចំណុចនីមួយៗត្រប់មេរៀន

ជំពូកទី១ ប្រវត្តិសាស្ត្រកម្ពុជាសម័យបុរេប្រវត្តិ

មុនអង្គរ និងអង្គរ




ការធ្វើកំណាយនៅស្ថានីយល្អាងស្ពាន



រូបសំណាកព្រះថោងតោងស្បែនាងនាគ



ប្រាសាទសំបូរព្រៃគុក



រូបសំណាកព្រះបាទជ័យវរ្ម័នទី៧

មេរៀនទី១ មូលដ្ឋាននៃការសិក្សាប្រវត្តិវិទ្យា

១-ពាក្យគន្លឹះ

- **មូលដ្ឋាន៖** ទីដែលជាឫសគល់ គោលការណ៍សំខាន់។
- **ឧត្តមគតិ៖** ចិត្តគំនិតខ្ពង់ខ្ពស់ អាស្រ័យដែលដុះដាលចេញមកដើម្បីរកសេចក្តីសុខ ចម្រើន, គោលបំណងឱ្យបានល្អប្រពៃ។
- **ជាតិនិយម៖** គំនិត ឬទស្សនៈដែលលើកតម្កើងជាតិសាសន៍ខ្លួនឯងឱ្យដាច់គេ, ការបន្ទាបតម្លៃជាតិសាសន៍ដទៃជាងជាតិសាសន៍ខ្លួន។
- **អត្តសញ្ញាណជាតិ៖** លក្ខណៈពិសេសនៃជាតិមួយ ដែលភាគច្រើន
- **កុលសម្ព័ន្ធ៖** សម្ព័ន្ធនៃវង្សត្រកូល, ការចងស្ពានមេត្រីទាក់ទងគ្នា ពីត្រកូលមួយទៅត្រកូលមួយ។ មនុស្សដែលប្រមូលផ្តុំគ្នាជាវង្សត្រកូល ហើយបិតនៅក្រោមអំណាចមេតែមួយ។
- **សក្ខីកម្ម៖** ការផ្តល់ភស្តុតាង ការផ្តល់អំណះអំណាង ការផ្តល់ចម្លើយក្នុងនាមជាសាក្សី។

២-ប្រវត្តិវិទ្យាជាអ្វី?

២.១-និយមន័យ

- **ប្រវត្តិវិទ្យា** គឺជាការសិក្សាអំពីហេតុការណ៍ ព្រឹត្តិការណ៍ បទពិសោធអតីតកាលរបស់មនុស្សជាតិដោយពឹងផ្អែកលើកំណត់ត្រា និងសក្ខីកម្មសម្រាប់សហសម័យ។
- **ប្រវត្តិវិទ្យា** គឺជាវិទ្យាសាស្ត្រ ឬមុខវិជ្ជាដែលសិក្សាអំពីហេតុការណ៍ ឬព្រឹត្តិការណ៍ ដែលបានកើតឡើងចាប់ពីពេលមនុស្សចេះប្រើប្រាស់អក្សរ។

- **ប្រវត្តិវិទ្យា** ជាវិទ្យាស្ស្រាវជ្រាវពីជីវភាពរស់នៅរបស់មនុស្សក្នុងពិភពលោក ជាច្រើនសម័យកាលកន្លងមក។ វិជ្ជានេះសិក្សាពន្យល់ពីមូលហេតុផ្សេងៗ ដោយប្រើឧបករណ៍របស់វិទ្យាស្ស្រាវជ្រាវដូចជា វិជ្ជាអក្សរបុរាណ សិលាចារឹក ទស្សនវិជ្ជា កាលប្រវត្តិវិទ្យា ជាតិពន្ធុវិទ្យា និងភូមិវិទ្យាជាដើម ។

- **បុរេប្រវត្តិសាស្ត្រ** គឺជាការសិក្សាអំពីអតីតកាលដ៏យូរលង់ណាស់មកហើយ តាំងពីមិនទាន់មានអក្សរ កំណត់ត្រា តែយើងអាចសិក្សាបានដោយផ្អែកលើរបាយការណ៍ផ្អែកបុរាណវិទ្យា។ សិក្សាពីអតីតកាលរបស់មនុស្សដោយផ្អែកលើ៖ ឧបករណ៍ប្រើប្រាស់ វត្ថុសិល្បៈ និងវត្ថុដែលគេបន្សល់ទុកមុនពេលមានឯកសារសរសេរ។

២.២-ឯកសារប្រវត្តិវិទ្យា

១-តើប្រវត្តិវិទូអាចដឹងពីប្រវត្តិសាស្ត្រតាមរយៈអ្វីខ្លះ?

- **ឯកសារសរសេរ៖** មានកំណត់ត្រាជនបរទេស សិលាចារឹក សាស្ត្រាស្លឹករឹត។
- **ឯកសារគ ឬបុរាណវត្ថុ៖** មានដូចជាសំណង់ រូបគំនូរ វត្ថុសិល្បៈ វត្ថុប្រើប្រាស់ (ថូ ចាន ពូថៅ ញញួរ កាំបិត គ្រឿងអលង្ការ...) ដែលបន្សល់ទុក និងសិក្សាដោយបុរាណវិទូ ។
- **ឯកសាររឿងនិទាន៖** រឿងប្រជាប្រិយតៗគ្នា ឬរឿងប្រវត្តិសាស្ត្រមានដូចជាព្រះថោងនាងនាគ ឥសីកម្ពុនិងទេពអប្សរមេរា។ ប៉ុន្តែការប្រើប្រាស់រឿងនិទានត្រូវពឹងផ្អែកទៅលើឯកសារ ទីតាំងភូមិសាស្ត្រជាក់ស្តែងទើបអាចសន្និដ្ឋានបាន។

២.៣-សារៈសំខាន់នៃប្រវត្តិវិទ្យា

១-តើការសិក្សាប្រវត្តិវិទ្យាផ្តល់នូវសារប្រយោជន៍ និងតុណតម្លៃអ្វីខ្លះ ?

- **តម្លៃអប់រំ និងជំនឿ:** ឱ្យអ្នកសិក្សាប្រកាន់យកគំរូល្អ និងមានឧត្តមគតិជាតិនិយមស្នេហាជាតិ ព្រមទាំងឆន្ទៈចូលរួមការពារជាតិមាតុភូមិ។
- **តម្លៃវប្បធម៌:** ឱ្យអ្នកសិក្សាស្រឡាញ់អត្តសញ្ញាណ បេតិកភណ្ឌជាតិ អរិយធម៌ជាតិ និងអន្តរជាតិ ទទួលខុសត្រូវចំពោះរាល់ការប្រព្រឹត្តរបស់ខ្លួន បង្កើនការយល់ដឹងពីអតីតកាល ដើម្បីរៀបចំអនាគតកាលឱ្យកាន់តែប្រសើរឡើង និងជៀសវាងកំហុសច្រំដែល។
- **តម្លៃសីលធម៌:** តម្លៃមនុស្សធម៌ តម្លៃសុជីវធម៌ ឱ្យអ្នកសិក្សាមានមនោសញ្ចេតនាសាមគ្គីភាពជាតិ អន្តរជាតិ និងទំនាក់ទំនងល្អជាសកល មិនរើសអើងជាតិសាសន៍ បណ្តុះស្មារតីកតញ្ញូតវេទីត្រិះរិះពិចារណារកផ្លូវវិជ្ជមានសម្រាប់ជាតិ និងក្លាយជាពលរដ្ឋល្អ និងពលរដ្ឋសកលប្រកបដោយការទទួលខុសត្រូវ ដើម្បីធានានិរន្តរភាព និងសុខដុមភាពនៃប្រជាជាតិរបស់ខ្លួន។

៣-កាលវិទ្យា

៣.១-និយមន័យ

- **កាលវិទ្យា** ជាវិជ្ជាដែលសិក្សាអំពីកាលបរិច្ឆេ(ថ្ងៃ ខែ ឆ្នាំ) សម្រាប់ចុះកាលកំណត់នៃហេតុការណ៍សំខាន់ៗណាមួយ ដើម្បីឱ្យអ្នកសិក្សាដឹងពីរយៈពេលនៃព្រឹត្តិការណ៍ទាំងនោះ។ ***ឧទាហរណ៍:*** ប្រទេសកម្ពុជាទទួលបានឯករាជ្យពេញលេញពីបារាំងនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។

៣.២-របៀបចែកកាល

១-តើគេបែងចែកកាលជាប៉ុន្មាន? អ្វីខ្លះ? ចូររៀបរាប់។

◆ **គេបែងចែកជាពីរគឺ៖**

១-សករាជ៖ គ្រប់កាលវិទ្យាទាំងអស់ត្រូវតែមានដើមទី១នៃសករាជ។

- **ក្រិកសករាជ៖** កំណើតល្បែងអូឡាំពិក ៧៧៦ មុនគ.ស. នៅប្រទេសក្រិក។
- **រ៉ូមសករាជ៖** កំណើតក្រុងរ៉ូម ៧៥៣ មុនគ.ស.
- **ពុទ្ធសករាជ៖** គិតចាប់ពីឆ្នាំ៥៤៣ មុនគ.ស. ពេលដែលព្រះពុទ្ធចូលនិព្វាន។
- **គ្រិស្តសករាជ៖** គិតចាប់ពីឆ្នាំទី១ នៃកំណើតព្រះយេស៊ូគ្រិស្ត។
- **មហាម៉ាត់សករាជ៖** (អ៊ិស្លាម) គិតចាប់ពីឆ្នាំ៦២២ ពេលដែលមហាម៉ាត់រត់គេចពីសត្រូវពីក្រុងឡាមុិចទៅក្រុងមេឌីន។ មហាម៉ាត់សករាជមានដើមទីហៅថា អេសៀ (égire) ជាកាល បរិច្ឆេទនៃការរត់គេចខ្លួនរបស់មហាម៉ាត់ពីទីក្រុងឡាមុិចនៅឆ្នាំ៦២២ ដោយមានការប្រឆាំងពីបច្ចាមិត្ត។
- **មហាសករាជ៖** ១៥ មិថុនា ៧៨ ព្រះបាទស្រុតវម្ម៌។
- **ចុល្លសករាជ៖** ១៦ឬ១៧មេសា ៦៣៨ ព្រះបាទឥសានវម្ម៌។
- **សាធារណរដ្ឋសករាជ៖** នៅពេលដែលប្រទេសបារាំងប្រកាសសាធារណរដ្ឋថ្ងៃទី២២ ខែកញ្ញា ១៧៩២។



២-រង្វាស់ពេល៖ គប្បីចងចាំនូវពាក្យសំខាន់ៗដូចខាងក្រោម៖

- ទសវត្ស (១០ឆ្នាំ)

- សតវត្ស (១០០ឆ្នាំ)
- សហស្សវត្ស (១០០០ឆ្នាំ) ។
- ប្រតិទិនចន្ទគតិមាន២៩ ឬ៣០ថ្ងៃ /១ខែ (គិតតាមដំណើរព្រះចន្ទ ៣ឆ្នាំលើកខែម្តង)។
- ប្រតិទិនសុរិយគតិមាន ៣០ឬ ៣១ ថ្ងៃ /១ ខែ (គិតតាមដំណើរព្រះអាទិត្យ ខែកុម្ភៈ២៨ ឬ២៩ថ្ងៃ)។

★ **<u>ការរាប់សហស្សវត្ស សតវត្ស និងទសវត្ស ជាពីរទម្រង់ដូចជាៈ</u>**

ក.ឆ្នាំនៃគ.ស.

★ *ទម្រង់ទី១* ស.វទី១នៃគ.ស. គឺរាប់ចាប់ពីឆ្នាំ ១-១០០ (ឆ្នាំរាប់ទៅមុខជាលំដាប់)។

★ *ទម្រង់ទី២* ស.វទី១នៃគ.ស. គឺរាប់ចាប់ពីឆ្នាំ ០-៩៩ (ឆ្នាំរាប់ទៅមុខជាលំដាប់)។

ខ.ឆ្នាំមុនគ.ស.

★ *ទម្រង់ទី១* ស.វទី១មុនគ.ស. គឺរាប់ចាប់ពីឆ្នាំ ១០០-១ (ឆ្នាំរាប់ថយក្រោយជាលំដាប់)

★ *ទម្រង់ទី១* ស.វទី១មុនគ.ស. គឺរាប់ចាប់ពីឆ្នាំ ៩៩-០ (ឆ្នាំរាប់ថយក្រោយជាលំដាប់)

★ **បញ្ជាក់ៈ** ដោយសារពិភពលោកបានកំណត់យកគ្រិស្តសករាជជាសកលរាជសកល ដូច្នេះព្រឹត្តិការណ៍ ឬឆ្នាំទាំងឡាយណាដែលបានកើតឡើងនៅមុនគ.ស.គឺត្រូវរាប់ថយក្រោយ ចំណែកព្រឹត្តិការណ៍ ឬឆ្នាំទាំងឡាយណាដែលកើតឡើងបន្ទាប់ពីគ.ស. ត្រូវរាប់ទៅមុខជាលំដាប់។

★ **បញ្ជាក់** កាលម៉ោង ១២ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០០ ឆ្លងចូលភ្លាម គេរាប់ចូលសហវត្សរ៍ទី៣ ជាស្រេចគឺសតវត្សរ៍ទី២១។


★ **ដើម្បីដឹងថា** ឆ្នាំមួយណាស្ថិតនៅក្នុងសតវត្សរ៍ណា គេត្រូវយកលេខចាប់ពីខ្ទង់រយ +១

◆ **ឧទាហរណ៍**

- ឆ្នាំ៥0=**0**៥0=**0**+១=ស.វ.ទី១
- ឆ្នាំ**៨**0២=**៨**+១=ស.វ.ទី៩
- ឆ្នាំ**២0**២៤=**២0**+១=ស.វ.ទី២១

ឆ្នាំ	...	-3	-2	-1	1	2	...	99	100	101	102	...	199	200	201	202	...
ទម្រង់ទី១		មុនគ.ស.			ស.វ.ទី១នៃគ.ស.					ស.វ.ទី២នៃគ.ស.					ស.វ.ទី៣នៃគ.ស.		
ទម្រង់ទី២					ស.វ.ទី១នៃគ.ស.					ស.វ.ទី២នៃគ.ស.					ស.វ.ទី៣នៃគ.ស.		

- ដើម្បីដឹងពីរយៈពេលនៃការគ្រប់គ្រងប្រទេស ឬការធ្វើកិច្ចការអ្វីមួយ យើងត្រូវយកកាលបរិច្ឆេទខាងចុងដក(-) កាលបរិច្ឆេទដំបូង។
- ឧ.របបកម្ពុជាប្រជាធិបតេយ្យមានរយៈពេល៣ឆ្នាំ ៨ខែ ២0ថ្ងៃ។
- ការដកគឺយើងដកពីឆ្វេង ទៅស្តាំ (ថ្ងៃទី/ខែ/ឆ្នាំ) បើលេខខាងលើតូចជា យើងត្រូវខ្ចីខែ(ខ្ចីមួយខែ) ខ្ចីឆ្នាំ (ខ្ចីមួយឆ្នាំ)។



$$\begin{array}{r} ๗\text{-}\ ๑\ \text{-}\ ๑๙๗๙ \\ \hline ๑๗\text{-}\ \ ๔\text{-}\ ๑๙๗๕ \\ \hline =๒๐\ \ ๘\ \ \ \ ๓ \end{array}$$

๒-ហេតុអ្វីបានជាការកំណត់ឆ្នាំក្នុងប្រវត្តិសាស្ត្រកម្ពុជាមានការខុសគ្នា១ឆ្នាំ ពីឯកសារមួយទៅឯកសារមួយ?

◆ **មូលហេតុនាំឱ្យមានកាលបរិច្ឆេទនៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រខុសគ្នា១ឆ្នាំ ពីឯកសារមួយទៅមួយទៀតដោយសារ៖**

- បារាំងដាក់អាណាព្យាបាលលើខ្មែរ បារាំងបានណែនាំ «គ្រិស្តសករាជ» ចាប់រាប់ឆ្នាំថ្មីពីថ្ងៃទី១ ខែមករា។ ប៉ុន្តែដោយខ្មែរធ្លាប់ប្រើ «សក:» ឬ «មហាសករាជ» រាប់ចាប់ពីថ្ងៃ ១កើត ខែចេត្រ (ក្រោយគ្រិស្តសករាជ ៧៨ឆ្នាំ)។
- បន្ទាប់មកនៅចុងសតវត្សទី១៦ ប្រើ «ពុទ្ធសករាជ» រាប់ចាប់ពីថ្ងៃ១រោច ខែពិសាខ (មុនគ្រិស្តសករាជ ៥៤៣ឆ្នាំ) និង «ចុល្លសករាជ» រាប់ចាប់ពីថ្ងៃ ១២កើត ខែចេត្រ (ក្រោយគ្រិស្តសករាជ ៣៦៨ឆ្នាំ)។
- ដូច្នេះ ១ឆ្នាំនៃមហាសករាជ ឬពុទ្ធសករាជ ឬចុល្លសករាជត្រូវស្ថិតនៅក្នុងគ្រិស្តសករាជ ២ឆ្នាំផ្សេងគ្នា។
- ***ឧទាហរណ៍៖*** តាមឯកសារពង្សាវតាខ្មែរ ព្រះបាទពញាយ៉ាតលើករាជធានីពីអង្គរទៅទួលបាសាននៅឆ្នាំ១៣៥៣ សក: ដោយពុំបានបញ្ជាក់ថាស្ថិតក្នុងខែអ្វី ទើបអ្នកប្រវត្តិសាស្ត្រខ្លះសន្និដ្ឋានថា ត្រូវនឹងគ.ស.១៤៣១ និងខ្លះទៀតនៅគ. ស.១៤៣២។

៣.៣-កាលសម័យចំៗនៃប្រវត្តិសាស្ត្រ

១-តើក្រុមប្រវត្តិវិទូលោកខាងលិចបានបែងចែកប្រវត្តិសាស្ត្រជាប៉ុន្មានកាលសម័យ? អ្វីខ្លះ?

◆ **បានបែងចែកជា២កាលសម័យគឺ៖**

- **កាលសម័យ** មានន័យខុសពីសម័យ។ កាលសម័យមានរយៈពេលវែងជាង ហើយបញ្ជាក់នូវចលនា និងវិវត្តន៍ក្នុងប្រវត្តិវិទ្យា។

១-កាលសម័យបុរេប្រវត្តិសាស្ត្រ

៤លានឆ្នាំមុនគ.ស. -៣២០០ឆ្នាំមុនគ.ស. (២លានឆ្នាំមុនគ. ស. -៣២០០ ឆ្នាំមុនគ.ស.)។

២-កាលសម័យប្រវត្តិសាស្ត្រ

- ***បុរាណសម័យ៖*** គិតចាប់តាំងពីឆ្នាំ៣២០០មុនគ. ស. រហូតដល់ឆ្នាំ ៤៧៦ ពេលដែលចក្រភពរ៉ូមខាងលិចដួលរលំ។
- ***មជ្ឈិមសម័យ៖*** គិតចាប់ពីឆ្នាំ១៣៩៥ (រ៉ូមចែកជា២) ឬ ៤៧៦ (រ៉ូមខាងលិចដួលរលំ) រហូតដល់ឆ្នាំ១៤៥៣ ពេលពួកអូតូម៉ង់វាយបានក្រុងកុងស្តង់ទីណូប ឬឆ្នាំ១៤៩២ ពេលដែលលោក គ្រីស្តូហ្វកូឡុំរកឃើញទ្វីបអាម៉េរិក។
- ***នវសម័យ៖*** គិតចាប់ពីឆ្នាំ១៤៥៣ ឬ ១៤៩២ ដល់ឆ្នាំ១៧៨៩ គឺជាឆ្នាំនៃបដិវត្តន៍បារាំង។
- ***សហសម័យ៖*** គិតចាប់ពីឆ្នាំ ១៧៨៩ រហូតមកដល់សព្វថ្ងៃនេះ ។

៤-កាលសម័យបុរេប្រវត្តិសាស្ត្រ

៤.១-យុគសម័យ

១-តើគេចែកកាលសម័យបុរេប្រវត្តិសាស្ត្រជាប៉ុន្មានយុគ? អ្វីខ្លះ?

◆ **គេចែកសម័យបុរេប្រវត្តិសាស្ត្រជា៣យុគសម័យមាន៖**

- **យុគថ្មបំបែក** (៤០០ ០០០ ឆ្នាំមុនគ.ស.- ១០ ០០០ ឆ្នាំមុនគ.ស.) មនុស្សបរិភោគសាច់ឆៅជាអាហារ។
- **យុគថ្មរំលីង** ១០ ០០០ ឆ្នាំមុនគ.ស.-៦០០០ឆ្នាំមុនគ.ស.) មនុស្សយកថ្មមកសំលៀងឱ្យមុតស្រួចទៅប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ។
- **យុគលោហៈ** ៦០០០ ឆ្នាំមុនគ.ស.- ១០០០ឆ្នាំមុនគ.ស.) មនុស្សយកលោហៈធ្វើជាឧបករណ៍ប្រើប្រាស់។

២-តើមូលដ្ឋាននៃការសិក្សាប្រវត្តិវិទ្យាមានអ្វីខ្លះ? ហេតុអ្វីបានជាចាំបាច់រៀនពីមូលដ្ឋាននៃប្រវត្តិវិទ្យា?

◆ **មូលដ្ឋាននៃការសិក្សាប្រវត្តិវិទ្យាមាន៖**

- ប្រភពឯកសារប្រវត្តិសាស្ត្រ (សិលាចារឹក សាស្ត្រាស្លឹករឹត កំណត់ត្រាជនបរទេស វត្ថុបុរាណ រឿងព្រេងនិទាន...)។
- កាលវិទ្យា(សកវាជ និងរង្វាស់ពេល)។
- បុរាណវិទ្យា(ថូ ចាន ពូថៅ ញញួរ កាំបិត គ្រឿងអលង្ការ...) ។

◆ **បានជាយើងចាំបាច់រៀនពីមូលដ្ឋាននៃប្រវត្តិវិទ្យាព្រោះ៖**

- ធានាបាននូវភាពត្រឹមត្រូវ និងសុក្រឹតភាពនៃការសិក្សាប្រវត្តិសាស្ត្រ។
- ជួយឱ្យយើងយល់ពីវិធីសាស្ត្រ និងឧបករណ៍ដែលប្រើប្រាស់ក្នុងការស្រាវជ្រាវប្រវត្តិសាស្ត្រ។
- មានមូលដ្ឋានរឹងមាំក្នុងការបកស្រាយ និងវិភាគព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ។

៣-ដូចម្តេចដែលហៅថាប្រភពឯកសារប្រវត្តិវិទ្យា?

- ***ប្រភពឯកសារប្រវត្តិវិទ្យា*** គឺជាភស្តុតាង ឬព័ត៌មានដែលត្រូវបានបង្កើតឡើងក្នុងអំឡុងពេល ឬបន្ទាប់ពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រណាមួយ ហើយត្រូវបានប្រើប្រាស់ដោយប្រវត្តិវិទូ ដើម្បីស្ថាបនាឡើងវិញនូវអតីតកាល។ ប្រភពឯកសារមានពីរគឺ ប្រភពឯកសារដើម និងប្រភពឯកសារទី២។

៤.២-ជីវភាពសង្គម

១-តើមនុស្សសម័យបុរេប្រវត្តិសាស្ត្រមានជីវភាពរស់នៅដូចម្តេច?

- **របៀបរស់នៅ** រស់នៅជាសហគមន៍ កុលសម្ព័ន្ធតាមរូងភ្នំ ឬសង់លំនៅតាមមាត់ទឹក។
- **ការវិឌ្ឍន៍នៃការរស់នៅ** ឈប់រស់នៅជាចរកជន ចេះធ្វើកសិកម្មប្រើសត្វគោ ក្របីជាកម្លាំងអូសទាញ។ ចេះផ្សាំងសត្វព្រៃធ្វើជាសត្វស្រុកមានដូចជា ឆ្កែគោ ចៀម ជ្រូក ជាដើម។
- **ឧបករណ៍ប្រើប្រាស់** ចេះធ្វើសិប្បកម្មផលិតអាវុធ និងឧបករណ៍ប្រើប្រាស់ផ្សេងៗដូចជាក្អម ឆ្នាំង កញ្ជើ ល្អី និងគ្រឿងអលង្ការគ្រប់ប្រភេទ។
- **ចំណេះដឹងផ្នែកស្ថាបត្យកម្ម** គេចេះសង់ប្រាសាទថ្មបញ្ឈរ ថ្មផ្តេក និងប្រាសាទថ្មបន្តុប។
- **ជំនឿ** មានជំនឿលើវត្ថុស័ក្តិសិទ្ធិ ឬបាតុភូតផ្សេងៗ ពិសេសជំនឿខាងបូជាសព។ មនុស្សស្លាប់ទៅគេយកទៅកប់ ជាមួយអាវុធ គ្រឿងអលង្ការ និងប្រដាប់ប្រដាប្រើប្រាស់។ ក្រោយមកគេមានជំនឿលើពហុទេពនិយម មានធម្មជាតិ និងសត្វជាដើម។

២-តើមនុស្សសម័យបុរេប្រវត្តិបន្សល់ទុកមរតកអ្វីខ្លះ ដល់យើងសព្វថ្ងៃ?

- ឧបករណ៍ប្រើប្រាស់ ដឹង ពូថៅ ចុងព្រួញ កាំបិត លំពែង ពន្លួញ ស្រួច ផ្លែកណ្តៀវ កញ្ជើ ថូ ភាជន៍ ឆ្នាំង ស្គរ គែន ទូក ច្បូង...
- របៀបធ្វើកសិកម្ម ចិញ្ចឹមសត្វ
- គំនូរលើជញ្ជាំងរូងភ្នំ
- ជំនឿលើវត្ថុសក្តិសិទ្ធិ បាតុភូតផ្សេងៗ ពហុទេពនិយម...
- ការប្រើប្រាស់ភ្លើង
- លំនៅឋានក្នុងរូងភ្នំ
- ឧបករណ៍ធ្វើពីថ្ម ឆ្អឹងសត្វ ដែក..។

៣-ហេតុអ្វីបានជាមួយសប្តាហ៍មាន៧ថ្ងៃ ? តើថ្ងៃណាជាថ្ងៃទី១នៃសប្តាហ៍ ?

- **តាមព្រះគម្ពីរបរិសុទ្ធ** ព្រះជាម្ចាស់បានបង្កើតអ្វីៗសព្វសារពើក្នុងរយៈពេល៦ថ្ងៃ ហើយថ្ងៃទី៧ ទ្រង់ញែកទុកជាថ្ងៃឈប់សម្រាក/ថ្ងៃបរិសុទ្ធ។
- **តាមទស្សនៈរបស់ពួកបាប៊ីឡូន** លេខ៧ជាលេខពិសេសតំណាងឱ្យតារាសក្តារៈទាំង៧ដែលគេតែងតែគោរពបូជា មានព្រះអាទិត្យ ព្រះចន្ទ ភពអង្គារ ភពពុធ ភពព្រហស្បតិ៍ ភពសុក្រ និងភពសៅរ៍។
- **អ្នកប្រាជ្ញពីបុរាណយល់ថា** ផែនដីស្ថិតនៅចំកណ្តាលសកល ហើយមានភពចំនួន៧ជាបរិវារវិលជុំវិញ។
- **តាមទស្សនៈរបស់ពួករ៉ូមបុរាណ** ប្រភពឈ្មោះថ្ងៃទាំង៧នេះបានមកពីឈ្មោះអាទិទេពទាំងប្រាំពីរដែលគេតែងតែគោរពបូជាតាំងពីដើមរៀងមកមានដូចជា Luna=Monday,


  Mercurii=Wednesday, Veneris=Friday, Solis=Sunday,

  Martis=Tuesday, Jovis=Thursday, Saturni=Santurday.

◆ ថ្ងៃទី១នៃសប្តាហ៍គឺ៖

- **លោក អឺម បូរិន្ទ** អ្នកស្រាវជ្រាវទំនៀមទម្លាប់ខ្មែរបានលើកឡើងថា ក្នុងការប្រើប្រាស់សព្វថ្ងៃទាំងផ្នែកផ្លូវរដ្ឋ ទាំងផ្នែកហោរាសាស្ត្រក៏ដូចគ្នា គឺគេចាប់ផ្តើមរាប់ថ្ងៃអាទិត្យជាថ្ងៃទី១ ចន្ទទី២..... និងថ្ងៃសៅរ៍ជាថ្ងៃទី៧ ។
- **តាមស្តង់ដាអន្តរជាតិ ISO 8601** បានកំណត់ថា ថ្ងៃចន្ទជាថ្ងៃទី១នៃសប្តាហ៍។


គំនិតអំពីសកល



ទស្សនៈរបស់អ្នកប្រាជ្ញជុំពីសម័យបុរាណរហូតដល់ស.ឥទ្ធី១៦ បានគិតថា

"ភពផែនដីយើងគឺស្ថិតនៅចំកណ្តាលនៃសកល ហើយមានភព
ចំនួន៧ជាបរិវារបានធ្វើដំណើរវិលជុំវិញផែនដីរបស់យើងនេះ"

នេះជាប្រភពនៃគំនិតមួយ បានបង្កើតរយៈពេលជាង៧ថ្ងៃ



ប៉ុន្តែចាប់ពីស.ឥទ្ធី១៧ មកគេបានសិក្សាស្រាវជ្រាវអកើញថា

"ព្រះអាទិត្យទៅវិញទេដែលស្ថិតនៅចំកណ្តាលសកល
ហើយមានភពផ្សេងៗចំនួន៨ បានធ្វើដំណើរវិលជុំវិញព្រះអាទិត្យ"

❑ ចូររាប់ឈ្មោះខែក្នុងប្រតិទិនចន្ទគតិ និងក្នុងប្រតិទិនសុរិយគតិ។

ឈ្មោះខែក្នុងប្រតិទិនចន្ទគតិ	ឈ្មោះខែក្នុងប្រតិទិនសុរិយគតិ
មិគ្គសិរ	មករា
បុស្ស	កុម្ភៈ
មាឃ	មីនា
ផល្គុន	មេសា
ចេត្រ	ឧសភា
ពិសាខ	មិថុនា

ជេស្ឋ	កក្កដា
អាសាឍ	សីហា
ស្រាពណ៍	កញ្ញា
ភទ្របទ	តុលា
អស្សុជ	វិច្ឆិកា
កត្តិក	ធ្នូ



តើខែណាខ្លះមាន ៣១ថ្ងៃ? ខែណាខ្លះមាន ៣០ថ្ងៃ?

៥-មេរៀនសង្ខេប

ការសិក្សាពីប្រវត្តិវិទ្យា គេត្រូវពឹងផ្អែកលើកំណត់ត្រា សិលាចារឹក និងប្រភពឯកសារផ្សេងៗមានដូចជាឧបករណ៍ប្រើប្រាស់ជាដើម។

តាមការសិក្សាបានឱ្យដឹងថា មនុស្សបុរេប្រវត្តិរស់នៅដោយស៊ីសាច់ឆៅ។ ក្រោយមកគេបានរកឃើញភ្លើងសម្រាប់ចម្អិនសាច់ ហើយប្រាជ្ញាស្មារតីមនុស្សក៏កាន់តែវិវឌ្ឍន៍ ដោយពួកគេចេះចិញ្ចឹមសត្វ ធ្វើកសិកម្ម គ្រឿងអលង្ការ សង់ផ្ទះ និងប្រាសាទ។

៦-សំណួរប្រតិបត្តិ

១-តើអ្វីទៅជាកាលវិទ្យា? គេចែកកាលសម័យដូចម្តេច?

២-តើមនុស្សដើមមានជីវិតតាំងពីយុគសម័យណា? គេចែកជាយុគអ្វីខ្លះ?

៣-តើនៅប្រទេសកម្ពុជាសព្វថ្ងៃគេប្រើប្រាស់សករាជអ្វីខ្លះ?

៤-ឯកសារសរសេរ ឯកសារគ និងឯកសាររឿងនិទាន ក្នុងចំណោមឯកសារប្រវត្តិសាស្ត្រទាំងបីនេះ តើប្រភពឯកសារមួយណាសំខាន់ជាងគេ? ព្រោះអ្វី?

៥-តើការសិក្សាប្រវត្តិវិទ្យាផ្តល់សារៈសំខាន់ដូចម្តេចខ្លះ?

ចេញ្ញាលក់ហ៊ីយ

ទំនាក់ទំនងតាមរយៈ

